# ការរក្សាការពារ ក្នុងរឿងក្តីរដ្ឋប្បវេណី ផ្នែក 3

ថ្ងៃទី 25 ខែមេសា ឆ្នាំ2018
ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់
MAEDA Yuta

# ឧទាហរណ៍អំពី
# ខ្លឹមសារនៃសេចក្ដីសម្រេចបញ្ចប់
# នៃការរក្សាការពារ
# ក្នុងរឿងក្ដីរដ្ឋប្បវេណី

# ឧទាហរណ៍អំពីខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់អំពីការរឹបអូសជាបណ្តោះអាសន្ន (ខ្លឹមសារនៃប្រយោគ)

## ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

| | |
|---|---|
| អត្តសញ្ញាណរបស់ភាគី | ដូចគ្នាទៅនឹងការសរសេរនៅក្នុងបញ្ជីសារពើភណ្ឌស្តីពីភាគី "សង្ខេប" |
| អត្តសញ្ញាណនៃសិទ្ធិលើបំណុលដែលទាមទារ | ដូចគ្នាទៅនឹងការសរសេរនៅក្នុងបញ្ជីសារពើភណ្ឌស្តីពីសិទ្ធិលើបំណុលដែលទាមទារ "សង្ខេប" |

ស្តីអំពី "លេខសំណុំរឿង និង ឈ្មោះសំណុំរឿង" រវាងគូភាគីខាងលើ តុលាការទទួលស្គាល់ថា ពាក្យសុំរបស់ម្ចាស់បំណុលមានភាពត្រឹមត្រូវ ដោយបង្គាប់ឲ្យម្ចាស់បំណុលដាក់ប្រាតិភោគនូវទឹកប្រាក់ចំនួន.............. ដុល្លារ និង ធ្វើការសម្រេចដូចតទៅ៖

# ឧទាហរណ៍អំពីខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់អំពីការរឹបអូសជាបណ្តោះអាសន្ន (សេចក្តីសម្រេចបញ្ចប់នៃការរឹបអូសជាបណ្តោះអាសន្ននូវអចលវត្ថុ)

រឹបអូសជាបណ្តោះអាសន្ននូវអចលនវត្ថុដែលបានសរសេរនៅក្នុងបញ្ជីសារពើភណ្ឌស្តីពី វត្ថុ "សង្ខេប" ដែលជាកម្មសិទ្ធិរបស់កូនបំណុល ដើម្បីរក្សាការពារនូវការអនុវត្តសិទ្ធិលើបំណុលខាងលើដែលម្ចាស់បំណុលមានចំពោះកូនបំណុល។

កូនបំណុលអាចទាមទារឲ្យលុបចោលនូវការចាត់ចែងការអនុវត្តនៃដីកាសម្រេចនេះបាន នៅពេលដែលបានផ្ញើប្រាក់ចំនួន.........ដុល្លារ។

# ឧទាហរណ៍អំពីខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់អំពីការរឹបអូសជាបណ្តោះអាសន្ន (សេចក្តីសម្រេចបញ្ចប់នៃការរឹបអូសជាបណ្តោះអាសន្ននូវសិទ្ធិលើបំណុល )

រឹបអូសជាបណ្តោះអាសន្ននូវសិទ្ធិលើបំណុលដែលបានសរសេរនៅក្នុងបញ្ជីសារពើភណ្ឌស្តីពី សិទ្ធិលើបំណុលដែលត្រូវរឹបអូសជាបណ្តោះអាសន្ន "សង្ខេប" ដែលកូនបំណុលមានចំពោះកូនបំណុលទី3 ដើម្បីរក្សាការពារនូវការអនុវត្តសិទ្ធិលើបំណុលខាងលើដែលម្ចាស់បំណុលមានចំពោះកូនបំណុល។

កូនបំណុលអាចទាមទារឲ្យលុបចោលនូវការចាត់ចែងការអនុវត្តជាបណ្តោះអាសន្ននៃដីកាសម្រេចនេះបាន នៅពេលដែលបានផ្ញើប្រាក់ស្មើនឹងចំនួនសិទ្ធិលើបំណុលដែលត្រូវរឹបអូសជាបណ្តោះអាសន្នខាងលើ។

※ នៅប្រទេសជប៉ុន តុលាការបានរួមបញ្ចូលនូវសេចក្តីសម្រេចបញ្ចប់ដែលមានខ្លឹមសារថា " កូនបំណុលទី3 មិនត្រូវបង់នូវកាតព្វកិច្ចដែលទាក់ទងនឹងការរឹបអូសជាបណ្តោះអាសន្នទៅឲ្យកូនបំណុលបានទេ" ។

# ឧទាហរណ៍អំពីខ្លឹមសារនៃសេចក្ដីសម្រេចបញ្ចប់អំពីការរឹបអូសជាបណ្ដោះអាសន្ន (សេចក្ដីសម្រេចបញ្ចប់នៃការរឹបអូសជាបណ្ដោះអាសន្ននូវចលនវត្ថុ)

រឹបអូសជាបណ្ដោះអាសន្ននូវចលនវត្ថុដែលកូនបំណុលមានកម្មសិទ្ធិត្រឹមចំនួនសិទ្ធិលើបំណុលដែលទាមទារខាងលើ ដើម្បីរក្សាការពារនូវការអនុវត្តសិទ្ធិលើបំណុលខាងលើដែលម្ចាស់បំណុលមានចំពោះកូនបំណុល។

កូនបំណុលអាចទាមទារឲ្យលុបចោលនូវការចាត់ចែងការអនុវត្តជាបណ្ដោះអាសន្ននៃដីកាសម្រេចនេះបាន នៅពេលដែលផ្ញើប្រាក់ស្មើនឹងចំនួនសិទ្ធិលើបំណុលដែលទាមទារខាងលើ។

# ឧទាហរណ៍អំពីខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់អំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ (ខ្លឹមសារនៃប្រយោគ)

## ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន

អត្តសញ្ញាណរបស់ភាគី ដូចគ្នាទៅនឹងការសរសេរនៅក្នុងបញ្ជីសារពើភណ្ឌស្តីពីភាគី "សង្ខេប"

ស្តីអំពី "លេខសំណុំរឿង និង ឈ្មោះសំណុំរឿង" រវាងគូភាគីខាងលើ តុលាការទទួលស្គាល់ថា ពាក្យសុំរបស់ម្ចាស់បំណុលមានភាពត្រឹមត្រូវ ដោយបង្គាប់ឲ្យម្ចាស់បំណុលដាក់ប្រាតិភោគនូវទឹកប្រាក់ចំនួន...............ដុល្លារ និង ធ្វើការសម្រេចដូចតទៅ៖

# ឧទាហរណ៍អំពីខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់អំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ (ទម្រង់ដែលស្តីអំពីការប្រើប្រាស់របស់កូនបំណុល)

កូនបំណុលមិនត្រូវផ្ទេរការកាន់កាប់ ឬ ផ្លាស់ប្តូរឈ្មោះនៃការកាន់កាប់លើវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភណ្ឌស្តីពី វត្ថុ "សង្ខេប" ឲ្យទៅតតិយជនទេ។

កូនបំណុលត្រូវតែលះបង់ការកាន់កាប់វត្ថុខាងលើ ហើយប្រគល់វត្ថុនេះឲ្យទៅអាជ្ញាសាលា។

អាជ្ញាសាលាត្រូវតែថែរក្សាគ្រប់គ្រងវត្ថុខាងលើ។

អាជ្ញាសាលាត្រូវតែអនុញ្ញាតឲ្យកូនបំណុលប្រើប្រាស់វត្ថុខាងលើ។

អាជ្ញាសាលាត្រូវតែប្រកាសជាសាធារណៈអំពី ការហាមឃាត់កូនបំណុលមិនឲ្យផ្ទេរការកាន់កាប់ ឬ ផ្លាស់ប្តូរឈ្មោះក្នុងការកាន់កាប់លើវត្ថុខាងលើ និង អំពីការដែលអាជ្ញាសាលាកំពុងគ្រប់គ្រងលើវត្ថុខាងលើ។

# ឧទាហរណ៍អំពីខ្លឹមសារនៃសេចក្ដីសម្រេចបញ្ចប់អំពីការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ (ទម្រង់ដែលស្ដីអំពីការគ្រប់គ្រងរបស់អាជ្ញាសាលា)

កូនបំណុលមិនត្រូវផ្ទេរការកាន់កាប់លើវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភណ្ឌស្ដីពី វត្ថុ "សង្ខេប" ឲ្យទៅតតិយជន ឬ ផ្លាស់ប្ដូរឈ្មោះក្នុងការកាន់កាប់ទេ។

កូនបំណុលត្រូវតែលះបង់ការកាន់កាប់នៃវត្ថុខាងលើ ហើយប្រគល់វត្ថុនេះ ឲ្យទៅអាជ្ញាសាលា។

អាជ្ញាសាលាត្រូវតែថែរក្សាគ្រប់គ្រងវត្ថុខាងលើ។

អាជ្ញាសាលាត្រូវតែប្រកាសជាសាធារណៈអំពី ការហាមឃាត់កូនបំណុលមិនឲ្យផ្ទេរការកាន់កាប់ ឬ ផ្លាស់ប្ដូរឈ្មោះក្នុងការកាន់កាប់លើវត្ថុខាងលើ និង អំពីការដែលអាជ្ញាសាលាកំពុងគ្រប់គ្រងលើវត្ថុខាងលើ។

# ឧទាហរណ៍អំពីខ្លឹមសារនៃសេចក្តីសម្រេចបញ្ឈប់អំពី ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ (ទម្រង់ដែលស្តីអំពីការប្រើប្រាស់របស់ម្ចាស់បំណុល)

កូនបំណុលមិនត្រូវផ្ទេរការកាន់កាប់លើវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភណ្ឌស្តីពី វត្ថុ "សង្ខេប" ឲ្យទៅតតិយជន ឬ ផ្លាស់ប្តូរឈ្មោះក្នុងការកាន់កាប់ទេ។

កូនបំណុលត្រូវតែលះបង់ការកាន់កាប់នៃវត្ថុខាងលើ ហើយប្រគល់វត្ថុនេះឲ្យទៅអាជ្ញាសាលា។

អាជ្ញាសាលាត្រូវតែថែរក្សាគ្រប់គ្រងវត្ថុខាងលើ។

អាជ្ញាសាលាត្រូវតែអនុញ្ញាតឲ្យម្ចាស់បំណុលប្រើប្រាស់វត្ថុខាងលើ។

អាជ្ញាសាលាត្រូវតែប្រកាសជាសាធារណៈអំពី ការហាមឃាត់កូនបំណុលមិនឲ្យផ្ទេរការកាន់កាប់ ឬ ផ្លាស់ប្តូរឈ្មោះក្នុងការកាន់កាប់លើវត្ថុខាងលើ និង  អំពីការដែលអាជ្ញាសាលាកំពុងគ្រប់គ្រងលើវត្ថុខាងលើ។

# ឧទាហរណ៍អំពីខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់អំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង (ខ្លឹមសារនៃប្រយោគ)

## ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន

អត្តសញ្ញាណរបស់ភាគី ដូចគ្នាទៅនឹងការសរសេរនៅក្នុងបញ្ជីសារពើភណ្ឌស្តីពីភាគី "សង្ខេប"

ស្តីអំពី "លេខសំណុំរឿង និង ឈ្មោះសំណុំរឿង" រវាងគូភាគីខាងលើ តុលាការទទួលស្គាល់ថា ពាក្យសុំរបស់ម្ចាស់បំណុលមានភាពត្រឹមត្រូវ ដោយបង្គាប់ឲ្យម្ចាស់បំណុលដាក់ប្រាតិភោគនូវទឹកប្រាក់ចំនួន..............ដុល្លារ និង ធ្វើការសម្រេចដូចតទៅ៖

# ឧទាហរណ៍អំពីខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់អំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង (សេចក្តីសម្រេចបញ្ជប់ )

កូនបំណុលមិនត្រូវធ្វើការចាត់ចែងណាមួយដូចជា អនុប្បទាន និងការបញ្ចាំ ឬ បង្កើតហ៊ីប៉ូតែកនិងសិទ្ធិជួល លើអចលនវត្ថុដែលបានសរសេរនៅក្នុងបញ្ជីសារពើភណ្ឌស្តីពីវត្ថុ "សង្ខេប" ទេ។

# ឧទាហរណ៍អំពីខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់អំពីការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់យ៉ាងជាបណ្តោះអាសន្ន (សេចក្តីសម្រេចបញ្ចប់)

1. ករណីនៃការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឲ្យបង់ប្រាក់ជាបណ្តោះអាសន្ន

កូនបំណុលត្រូវបង់ប្រាក់ជាបណ្តោះអាសន្នចំនួន.............ដុល្លារឲ្យទៅម្ចាស់បំណុល។

2. ករណីនៃការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឲ្យហាមឃាត់ការសាងសង់

កូនបំណុលមិនត្រូវធ្វើការសាងសង់អាគារដែលបានសរសេរក្នុងបញ្ជី(2) ទៅលើដីដែលបានសរសេរនៅក្នុងបញ្ជី (1) នៃបញ្ជីសារពើភណ្ឌស្តីពីវត្ថុ "សង្ខេប" ទេ។